ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤

លេខ: ១១

ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ **នាមនាមប្រជារាស្ត្រខ្មែរ**

**សាលដីកា** **តុលាការកំពូល**

លេខ: ១៩២ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៨ ខែកញ្ញា

ចុះថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ២០០៣ ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឃឹម ប៊ុណ្ណា** ជាប្រធាន

២-លោក ស៊ិន ឌីម ជាចៅក្រម

៣-លោក ប្រាក់ គីមសាន ជាចៅក្រម

៤-លោក ជីវ កេង ជាចៅក្រម

៥-លោក ប៉ែន សារឿន ជាចៅក្រមរបាយការណ៍

៦-លោក សោម សិរីវឌ្ឍ ជាចៅក្រម

៧-លោក ឈឹម ស៊ីផល ជាចៅក្រម

៨-លោក យស់ សូខឿន ជាចៅក្រម

៩-លោក ម៉ុង មុនីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

លោក **សុខ ម៉ៅ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ ៤៥ "ឈ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **អ៊ុំ ចន្ទធារី** (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤៤ ឆ្នាំ (ស) ជាតិខ្មែរ មុខរបរមន្ត្រីរាជការរដ្ឋសភាជាតិ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦៧៩ Eo ផ្លូវលេខ ១២៨ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ៕

ផ្ទេរសិទ្ធិឱ្យឈ្មោះសេងសុវត្ថា អាយុ៤៣ឆ្នាំ មុខរបរប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋាន រដ្ឋសភា ។

ចុងចំលើយឈ្មោះ **ហ្គា ហ្គណូ អាល់ប៊ែ**(ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៥៣ឆ្នាំ(ស)

ផ្ទេរសិទ្ធិឱ្យមេធាវីឈ្មោះម៉ៅ សំវុទ្ធារី អាស័យដ្ឋាន ផ្ទះលេខ៤៥ មហាវិថីព្រះសុរាម្រិត សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

តតិយជនអ្នកស្រី គង់ យន់ អាយុ៨១ឆ្នាំ ជាម្តាយបង្កើតរបស់អាល់ប៊ែរហ្គាហ្គាណូ ។

មានមេធាវី លោក ពុធ ធារី ។

<u>**កម្មវត្ថុបណ្តឹង**</u> : ប្តឹងសុំលែងលះ

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១១ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខលើកទី២លេខ ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវីឈ្មោះម៉ៅ សំវុទ្ធារី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៥"ឈ"ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះអ៊ីគន្ធនារី ប្តឹងលែងលះប្តីឈ្មោះហ្គាហ្គាណូ អាល់ប៊ែរ ដោយសំអាងហេតុថា : ប្តីមិនគិតគូរគ្រួសារអ្វីទាំងអស់ ប្រព្រឹត្តអំពើថ្មយសីលធម៌ស្រវឹង មកផ្ទះវិញរករឿងប្រពន្ធកូន ជេរបញ្ចោ អាសអាភាស ជេរប្រមាថធ្ងន់ធ្ងរ ចំពោះបុព្វញាតិរបស់ខ្លួន ធ្វើទុក្ខបុកម្នេញខ្លួនស្ទើររាល់ថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៣"ក"ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះអ៊ី គន្ធនារី ចុះថ្ងៃទី១៥-១០-១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ឱ្យឈ្មោះ អ៊ី គន្ធនារី និង ឈ្មោះហ្គាហ្គាណូ អាល់ប៊ែរ ដាច់សមគ្គសង្វាសពីគ្នាតាមការព្រមព្រៀងគ្នា ចាប់ពីថ្ងៃប្រកាសាលក្រមនេះតទៅ តាមមាត្រា៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារចុះថ្ងៃទី២០-៧-១៩៨៩ ។

៣-ឱ្យនារី អ៊ី គន្ធនារី ស្ថិតនៅក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារចុះថ្ងៃទី២០-៧-១៩៨៩ ។

៤-បែងចែកទ្រព្យសម្បត្តិភាគហ៊ុនរួមមានផ្ទះលេខ៥២E₀ស្ថិតនៅផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មី២ ខ័ណ្ឌដូនពេញ និង ផ្ទះលេខ៣៥ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ជាពីរចំណែកស្មើគ្នា តាមតំលៃជាក់ស្តែង គិតពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ ។

៥-បង្គាប់ឱ្យឈ្មោះអ៊ី គន្ធនារី បង់ប្រាក់ប្រដាប់ក្ដី៧.០០០៛ គឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ្វ៊ីង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ ។ប្រាក់នេះដើមចោទបានបង់រួចហើយ ។ កាលបើហួសបណ្ដឹងឧទ្ធរណ៍បង្គាប់ឱ្យឈ្មោះហ្គាហ្គាណូអាល់ប៊ែរ សងប្រាក់៧.០០០៛ នេះទៅដើមចោទវិញ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខភាគី សំរេចបើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៦៩"ក"ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ១៩៩៩ របស់មេធាវីឈ្មោះ មៀចសំអាន់ ការពារឱ្យដើមចោទ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៣"ក" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៤ នៃសេចក្ដីសំរេចរបស់សាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០២"ក"ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកមៀច សំអាន់ ជាមេធាវី ថណាយក្ដីឱ្យឈ្មោះ អ៊ី គន្ធនារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ៩៣"ក"ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុង ទុកជាបានការពេញទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះអ៊ី គន្ធនារី ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០២"ក"ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ០៦ ខែមិនា ឆ្នាំ២០០១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ ១៦ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០០ របស់អ្នកស្រីអ៊ី គន្ធនារី ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់៚

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ០២"ក"ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៥០ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលអ្នកស្រីអ៊ី គន្ធនារី បានបង់ទុកជាមុនគឺ

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតំរូវឱ្យលោក ហ្គាហ្គាណូ អាល់ប៊ែរ សងប្រាក់ចំនួន ១៩.០០០៛ នេះទៅឱ្យអ្នកស្រីអ៊ី គន្ធនារីវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមិនា ឆ្នាំ២០០១។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៥"ឈ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ០៦ ខែមិនា ឆ្នាំ២០០១ របស់តុលាការកំពូល ។

២-សំរេចចាត់បញ្ចូលឈ្មោះ កង យន់ ភេទស្រី អាយុ៨១ឆ្នាំ មកជាទាយាទ ខាងភាគីចុងចំលើយ ។

៣-សំរេចចាត់បញ្ចូលឈ្មោះភិរម្យ គន្ធលក្ខស្មី ភេទស្រី អាយុ ២២ឆ្នាំ និង ឈ្មោះភិរម្យ វឌ្ឍនា ភេទប្រុស អាយុ២០ឆ្នាំ មកជាទាយាទខាងភាគីដើមចោទ ។

៤-ទទួលស្គាល់ផ្ទះលេខ ៥២E០ ផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មីទី២ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៤៥២៧ ចុះថ្ងៃទី២១-៩-១៩៩១ របស់គណៈកម្មាធិការប្រជាជនរាជធានីភ្នំពេញ និងផ្ទះលេខ ៣៥ ផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៣៨៧ ចុះថ្ងៃទី២៥-០៣-១៩៩១ របស់គណៈកម្មាធិកាប្រជាជនរាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់សពឈ្មោះអ៊ី គន្ធនារី នៅពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

៥-ប្រគល់ផ្ទះលេខ៥២E០ ផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មីទី២ ខ័ណ្ឌដូនពេញដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៤៥២៧ ចុះថ្ងៃទី២១-៩-១៩៩១និងផ្ទះលេខ ៣៥ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ...

លេខ១៣៨៧ ចុះថ្ងៃទី២៥-០៣-១៩៩១ ឱ្យទៅឈ្មោះភិរម្យគន្ធលក្ខិស្មី និងឈ្មោះ ភិរម្យ វឌ្ឍនាដែល ជាទាយាទរបស់សពអ្នកស្រី អ៊ី គន្ធនារី កាន់កាប់ និងគ្រប់គ្រងតទៅ ។

៦-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលបណ្តឹងឧទ្ធរណ៍ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ រង្វាន់ អ្នកប្រគល់ដីកាកោះ ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ ។

៧-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះសេង សុវត្ថា ភិរម្យ គន្ធលក្ខិស្មី , ភិរម្យ វឌ្ឍនា និងចំពោះមុខមេធាវីតំណាងចុងចំលើយឈ្មោះម៉ៅ សិរីវុទ្ធារី ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខលើកទី២លេខ ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់ មេធាវីឈ្មោះម៉ៅ សិរីវុទ្ធារី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៥"ឈ"ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣របស់ឈ្មោះម៉ៅ សិរីវុទ្ធារីជាមេធាវី ការពារឱ្យចុងចំលើយ ។

បានឃើញសារណាឆ្លើយតបចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះសេង សុវត្ថា ជា តំណាងឱ្យដើមចោទ ។

បានឃើញសារណាការពារបន្ថែមចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះ ពុធ ធារី ជាមេធាវីការពារឱ្យចុងចំលើយ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

តាងនាមតំណាងមហាអយ្យការ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ចុះ ។

បានស្តាប់ក្រឡាបញ្ជីអានសារណាការពារ របស់ឈ្មោះ ម៉ៅ សិរីវុទ្ធារី និងសារណារបស់ឈ្មោះ ពុធ ធារី ជាមេធាវីការពារអោយចុងចំលើយ និងតតិយជនចុងចំលើយ នាពេលជំនុំជំរះ ។

បានស្តាប់ចំលើយរបស់ឈ្មោះ សេង សុវត្ថា តំណាងឱ្យដើមចោទ នាពេលសវនាការថា :

ការអះអាងរបស់ចុងចំលើយ និង តតិយជន បំផ្លើសហួសពីការពិត ព្រោះថា តាមទំលាប់ជន បរទេស មានលុយ គេទុកផ្ញើនៅធនាគារ មិនមាននរណាម្នាក់យកលុយឱ្យនរណាមួយទៀត ដោយមិន មានសំបុត្រនោះទេ បើចុងចំលើយមានលុយមែន គឺចុងចំលើយដាក់នៅឯធនាគារហើយ លោកមេធាវី អាចស្នើសុំស្រាវជ្រាវតាមលេខកុងនៅធនាគារប្រទេសបារាំងបានឃើញហើយ គឺគេស្រាវជ្រាវតែស្ថានភាព ហិរញ្ញវត្ថុរបស់បងស្រីខ្លួន ។ ឯស្ថានភាពហិរញ្ញវត្ថុ របស់លោកហ្គាហ្គាណូ អាល់ប៊ែរ អះអាងគ្មានការ/...

ពិតឡើយ ។ ម៉្យាងទៀត ផ្ទះបងស្រីខ្លួនទិញមានទំហំតូចណាស់ មិនសមនឹងលុយ២៥ម៉ឺនដុល្លារអាមេរិក ដែលចុងចំលើយបានអះអាងនោះទេ ។ ពីមុនមកមិនលេចឮរឿងនេះទេ លុះដល់ពេលលែងលះ ក៏ឮថា យកលុយ២៥ម៉ឺនដុល្លារអាមេរិកឱ្យទៅទិញផ្ទះទេវិញ ។ កិច្ចព្រមព្រៀងជួលផ្ទះគឺតំលៃ ១២៥០ ដុល្លា អាមេរិកក្នុងមួយខែ ខ្លួនមិនបានគិតទេ តែខ្លួនយល់ឃើញថា ប្រាក់ដែលតំកល់នៅតុលាការមិនបាត់ទៅ ណាទេ ខ្លួនយល់ថា តាំងពីតុលាការឱ្យតំកល់ និងលុយឃើញហើយ ។ គួរពិចារណាមើលថា គាត់គ្មានផ្ទះនៅបែរឱ្យលុយទៅគេទិញផ្ទះទេវិញ បើខ្លួនជិះកង់ មានរឿងអ្វីខ្លួនមានលុយទិញឡានCRV ឱ្យស្រីជិះនោះ ។

ខ្លួនសុំតំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ សុំផ្ទះ និងប្រាក់តំកល់នៅតុលាការក្រុងឱ្យ ទាយាទកូនទាំងពីរ ព្រោះនេះជាទ្រព្យដើមរបស់អ្នកស្រី អ៊ុំ គន្ធនារី ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់តំណាងចុងចំលើយ និងតំណាងតតិយជន ព្រម ទាំងចំលើយរបស់តំណាងដើមចោទ .
- ក្រោយពីបានពិភាក្សាគ្រប់ត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវី ម៉ៅ សំវុទ្ធារីធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តីនិងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការលើកឡើងក្នុងសារណាចុះថ្ងៃទី១០-៦-២០០៣ របស់មេធាវីម៉ៅសំវុទ្ធារី និងសារណាបន្ថែមរបស់មេធាវីពុធ ធាវី ដោយអះអាងថា : នៅក្នុងឆ្នាំ១៩៨៨លោកហ្គាហ្គាណូអាល់បែរ មកលេងស្រុកខ្មែរ ហើយបានប្រគល់ប្រាក់ចំនួន១២ម៉ឺនដុល្លារអាមេរិក ឱ្យទៅអ្នកស្រីអ៊ុំ គន្ធនារីសំរាប់ទិញ ផ្ទះនិងនៅឆ្នាំ១៩៩០ លោកហ្គាហ្គាណូអាល់បែរមកស្រុកខ្មែរម្តងទៀត ហើយក៏បានប្រគល់ប្រាក់ចំនួន១៣ ម៉ឺនដុល្លារអាមេរិកទៀត ឱ្យអ្នកស្រីអ៊ុំ គន្ធនារី សំរាប់ទិញហាងលក់គេសជ្ជៈ និងជួសជុលផ្ទះនោះ ពុំមាន ភស្តុតាង ណាមួយច្បាស់លាស់ដែលអាចឱ្យតុលាការកំពូលពិចារណាបានឡើយ ។

- យល់ឃើញថា ការដែលមេធាវីការពារអោយចុងចំលើយសុំបែងចែកទ្រព្យសម្បត្តិ ដែលមាន អចលនទ្រព្យ ផ្ទះលេខ៥២EoE1 ស្ថិតនៅផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ និងផ្ទះលេខ...

៣៥ ស្ថិតនៅផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក ជាពីរចំណែកស្មើគ្នា តាមស្មារតីនៃមាត្រា ៣៣ និង៣៤ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ នោះគឺជាការភាន់ច្រឡំ ពីព្រោះថា អចលនទ្រព្យទាំងពីរកន្លែងខាងលើនេះ ដែលមួយមានប័ណ្ណសំគាល់សិទ្ធិលេខ ៤៥២៨ ចុះថ្ងៃទី២១-៩-៩១ និងមួយទៀតមានប័ណ្ណសំគាល់សិទ្ធិលេខ១៣៨៧ ចុះថ្ងៃទី២៥-៣-៩១ គឺមានឈ្មោះអ្នកស្រីអ៊ី គន្ធនារី ជាម្ចាស់កម្មសិទ្ធិតែម្នាក់ឯង ដោយគ្មានបញ្ជាក់ថា ជាកម្មសិទ្ធិរួមប្តីប្រពន្ធនោះឡើយ ។ ដូច្នេះអចលនទ្រព្យទាំងពីរ គឺពិតជាទ្រព្យដើមរបស់អ្នកស្រី អ៊ី គន្ធនារី ដែលតាមច្បាប់ ត្រូវតែបានជាទ្រព្យដើមរបស់ភាគីដើមចោទ តែម្នាក់ឯងប៉ុណ្ណោះ ។ ម៉្យាងទៀត តាមប័ណ្ណសំគាល់សិទ្ធិនៃអចលនទ្រព្យទាំងពីរនេះគឺធ្វើនៅឆ្នាំ១៩៩១ រីឯគូភាគីទើបតែធ្វើប័ណ្ណទទួលស្គាល់អាពាហ៍ពិពាហ៍នៅថ្ងៃទី ៣០-០៨-៩៣ទេ គឺធ្វើក្រោយថ្ងៃទិញ និងថ្ងៃធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ ។

- យល់ឃើញថា ក្នុងការសំរេចសេចក្តីជាថ្មីឡើងវិញ សាលាឧទ្ធរណ៍ពុំបានពិចារណា និងសំរេចអំពីប្រាក់ឈ្នួលផ្ទះលេខ ៥២ E0 E1 ដែលតុលាការកំពូលសំរេចតាមសាលដីកាលេខ១០៩ប្រ ចុះថ្ងៃទី១៣-៦-២០០០ ត្រង់ចំណុចទី៣ ឱ្យអ្នកជួលផ្ទះយកប្រាក់ថ្លៃឈ្នួលផ្ទះលេខ៥២EoE1 ទៅតំកល់ទុកនៅតុលាការក្រុងភ្នំពេញទេ ដូច្នេះតុលាការកំពូលដែលជំនុំជំរះទាំងអង្គហេតុ និងអង្គច្បាប់ នៅពេលនេះគប្បីលើកយកប្រាក់ដែលតំកល់ទុកនៅតុលាការក្រុងភ្នំពេញមកសំរេច ។

- យល់ឃើញថា ក្នុងពេលដែលលោកហ្គាហ្គាណូអាល់ប៊ែរ និងអ្នកស្រីអ៊ី គន្ធនារី នៅរស់និងស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ លោកហ្គាហ្គាណូអាល់ប៊ែរបានបំពេញកិច្ចជាច្រើនដើម្បីផលប្រយោជន៍របស់គ្រួសារអ្នកស្រីអ៊ី គន្ធនារី ដូចជាធានាយកអ្នកស្រីអ៊ី គន្ធនារី ព្រមទាំងកូនអ្នកស្រីអ៊ីគន្ធនារីទាំងពីរនាក់ទៅរស់នៅប្រទេសបារាំងហើយ បំពេញកិច្ចធានារហូតដល់ម្តាយនិងកូននេះបានចូលជាសញ្ជាតិបារាំងទៀត ។ ប៉ុន្តែពេលនេះអ្នកស្រីអ៊ី គន្ធនារី បានទទួលមរណភាពទៅហើយ នៅសល់ទាយាទជាកូន០២នាក់ដែលត្រូវទទួលមរតកជាផ្ទះពីរកន្លែង និងថ្លៃឈ្នួលផ្ទះ ប៉ុន្តែលោកហ្គាហ្គាណូអាល់ប៊ែរ ក្រោយពេលទទួលមរណភាពទៅនៅសល់ទាយាទជាម្តាយដែលចាស់ជរាគ្មានទ្រព្យសម្បត្តិអ្វីដើម្បីរស់នៅបន្តភាពចាស់ជរារបស់ខ្លួនទេ ។ ដូច្នេះ ផ្អែកតាមគោលការណ៍ប្រព្រៃណីល្អ និងសមធម៌ ដែលមានចែងក្នុងមាត្រា៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៣៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និង គ្រួសារតុលាការកំពូល គប្បីសំរេចដកយកប្រាក់ថ្លៃឈ្នួលផ្ទះដែលតំកល់ទុកនៅតុលាការក្រុងភ្នំពេញខ្លះដែលបានជួលក្នុងពេលចំណងអាពាហ៍ពិពាហ៍មិនទាន់ត្រូវបានរំលាយ ឧបត្ថម្ភដល់តតិយជនជាទាយាទឈ្មោះកង យន់ ដើម្បីអាចបន្តជីវិតរស់នៅក្នុងភាពចាស់ជរា ។

- យល់ឃើញថា កម្មវត្ថុនៃការទាមទាររបស់គូភាគី គឺផ្ទះលេខ៣៥ ផ្ទះលេខ៥២ EoE1និងE2 ប៉ុន្តែសាលាឧទ្ធរណ៍បានសំរេចតែផ្ទះលេខ៣៥ និងលេខ ៥២Eo ប៉ុណ្ណោះ នៅពុំទាន់បានសំរេចអំពីផ្ទះ លេខ

លេខ ៥២E1 និង E2 ទេ ។ ប៉ុន្តែដោយតំណាងដើមចោទពុំបានប្តឹងសាទុក្ខពីសាលដីកាសាលាឧទ្ធរណ៍ ជាលើកទី២ទៀតនោះ តុលាការកំពូល ពុំមានសមត្ថកិច្ចលើកយកផ្ទះលេខ៥២E1 និង៥២E2 មកសំរេច បានទេ ។

- យល់ឃើញថា តំណាងចុងចំលើយនិងតំណាងតតិយជន បានធ្វើសារណាជូនមកតុលាការ កំពូលរួចហើយ ហើយក៏បានទទួលដីកាកោះឱ្យមកចូលរួមនាសវនាការនេះដែរ ប៉ុន្តែពុំបានមកចូលរួមនា សវនាការនេះទេដោយតំណាងតតិយជនសុំពន្យាពេលសវនាការដោយពុំមានភស្តុតាងច្បាស់លាស់ ដូច្នេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៨៥"ឈ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយដោយគ្រាន់តែសំរេចមិនអស់ នូវកម្មវត្ថុនៃរឿងទំនាស់ ដែលគប្បីតុលាការកំពូលសំរេចបន្ថែមឱ្យបានគ្រប់គ្រាន់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងដើមចោទកំបាំងមុខ**

**តំណាងចុងចំលើយ និងតំណាងតតិយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវី ម៉ៅ សំវុទ្ធារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៨៥ "ឈ" ចុះថ្ងៃទី២៦ ខែ មិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលដោយគ្រាន់តែបន្ថែមចំណុច :

ប្រាក់ថ្លៃឈ្នួលផ្ទះ ដែលបានតំកល់ទុកនៅតុលាការក្រុងភ្នំពេញ ត្រូវផ្តល់ជូនអ្នកស្រីកង យន់ ជាទាយាទរបស់លោក ហ្គាហ្គាណូអាល់ប៊ែរ ចំនួន ១៥.០០០ដុល្លាអាមេរិក(មួយម៉ឺនប្រាំពាន់គត់) ប្រាក់សល់ពីនេះត្រូវប្រគល់ឱ្យកូនទាំងពីរ ដែលជាទាយាទរបស់សពអ្នកស្រីអ៊ឹគន្ធនារី ទាំងអស់ ។ក្រោយ ពេលសាលដីកានេះចូលជាស្ថាពរទាយាទនៃសពអ្នកស្រីអ៊ឹ គន្ធនារី មានសិទ្ធិបើកប្រាក់ថ្លៃឈ្នួលផ្ទះដោយ ផ្ទាល់ពីអ្នកជួល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលតំណាងដើមចោទបានបង់ជួសនៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន៤.០០០៛ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជា រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយបង្គាប់ ឱ្យតំណាងចុងចំលើយសងប្រាក់ ១៩.០០០៛ នេះទៅតំណាងដើមចោទវិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៨ខែកញ្ញាឆ្នាំ២០០៣។